**ធ្វើការរួមគ្នាដើម្បីអោយ**
**ប្រសើរឡើងនូវគុណភាពជីវិតកសិករនិងទាំងអស់គ្នា**




**សូមទំនាក់ទំនងយើងខ្ញុំតាមរយៈ៖**

អាសយដ្ឋាន៖ ផ្ទះលេខ២៨ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

Facebook ៖ ខាំបូឌ្រា/Cambodhrra

អ៊ីម៉ែល ៖ cambodhrrainfo@gmail.com

លេខទូរសព្ទ៖ +855 17 451 564/+855 98 452 581


សមាគមភាពជាដៃគូកម្ពុជាដើម្បីអភិវឌ្ឍន៍ធនធានមនុស្សនៅជនបទ(**ខាំបូឌ្រា**) គឺជាវេទិកាបណ្តាញថ្នាក់ជាតិដែលប្រមូលផ្តុំស្ថាប័ននិងតួអង្គសំខាន់ៗទាក់ទងនឹងកសិកម្មនិងការអភិវឌ្ឍន៍ជនបទ ដើម្បីធ្វើការរួមគ្នាក្នុងការកែលម្អផលិតកម្មកសិកម្មនិងការផ្សារភ្ជាប់ទីផ្សារដែលផ្តល់ផលប្រយោជន៍ដល់កសិករ និងសហគមន៍របស់ពួកគេ។ **ខាំបូឌ្រា** បានផ្តួចផ្តើមបង្កើតឡើងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដោយបណ្តាញស្ថាប័នដែលធ្វើការទាក់ទងនឹងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ និងចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ ដែលមានសមាជិកចំនួន២១ស្ថាប័ន ក្នុងនោះមានអង្គការកសិករថ្នាក់ជាតិចំនួន៤ ក្រុមហ៊ុនឯកជនចំនួន៥ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចំនួន១២។

## ទស្សនៈវិស័យ

**ខាំបូឌ្រា** ចង់ឃើញកសិករកម្ពុជាមានគុណភាពជីវិត និង ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

## បេសកកម្ម

**ខាំបូឌ្រា** គាំទ្របច្ចេកទេសកសិពាណិជ្ជកម្ម និងអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន កៀរគរធនធាន សម្របសម្រួលបរិយាកាសអំណោយផលសម្រាប់អង្គការកសិករ និងពង្រឹងខ្សែសង្វាក់តម្លៃកសិកម្ម។

## គុណតម្លៃ

១- ទាំងអស់គ្នាមានជីវិតថ្លៃថ្នូរ
២- សហប្រតិបត្តិការ និងភាពជាដៃគូ
៣- បរិយាប័ន្ន
៤- តម្លាភាព និងគណនេយ្យភាព

## សមាជិក

សមាជិករបស់**ខាំបូឌ្រា**រួមមាន៖

១- អង្គការកសិករថ្នាក់ជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលគាំទ្រវិស័យកសិកម្ម រួមបញ្ចូលទាំងអង្គការយុវជន
២- ក្រុមហ៊ុនឯកជនដែលកំពុងធ្វើកសិធុរកិច្ច
៣- អង្គភាពជំនាញដែលធ្វើការនិងគាំទ្រវិស័យកសិកម្ម។

## គោលដៅជាយុទ្ធសាស្ត្រ

**ខាំបូឌ្រា** មានគោលបំណងដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រចំនួន ៤ រួមមាន៖

- លើកកំពស់សមត្ថភាពរបស់អង្គការកសិករលើផ្នែកបច្ចេកទេស ជំនួញ និងការអភិវឌ្ឍស្ថាប័ន។
- បង្កើនការទទួលបានទីផ្សារ និងដើមទុនវិនិយោគសម្រាប់អង្គការកសិករ។
- ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អាជីវកម្មរបស់កសិករ ដែលមានប្រសិទ្ធភាព និងចំណេញ។
- បង្កើនសមត្ថភាពរបស់ខាំបូឌ្រា ដើម្បីផ្តល់សេវាដល់សមាជិករបស់ខ្លួន ជាពិសេសអង្គការកសិករ។

គាំទ្រដោយ៖